# របាយការណ៍សង្ខេប
# ស្តីពី
# “វឌ្ឍនភាពមូលដ្ឋាន ឃុំ សង្កាត់ និងទិសដៅការងារបន្ត”
# របស់ឯកឧត្តម ឡុង ឈុនឡៃ ប្រធានក្រុមប្រឹក្សាខេត្តកំពង់ឆ្នាំង
# ថ្លែងក្នុងសន្និសីទសារព័ត៌មាន
# នៅទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២

ជាបឋម ខ្ញុំព្រះករុណា-ខ្ញុំបាទ៖

-សូមក្រាបថ្វាយបង្គំសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គ *ជាទីគោរពសក្ការៈ!*

-សូមក្រាបបង្គំទូលថ្វាយ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!*

-សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !*

-សូមគោរព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ *ជាទីគោរពដ៏ខ្ពង់ខ្ពស់!*

-សូមគោរព **ឯកឧត្តម ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល *ជាទីគោរព!*

-ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មាន ដែលមានវត្តមានផ្ទាល់នៅទីនេះ និងបងប្អូនប្រជាពលរដ្ឋដែលកំពុងទស្សនាការផ្សាយផ្ទាល់នាឱកាសពេលនេះ *ជាទីគោរពរាប់អាន!*

ថ្ងៃនេះតាងនាមក្រុមប្រឹក្សាខេត្តកំពង់ឆ្នាំង និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ខ្ញុំព្រះករុណា-ខ្ញុំបាទសូមសម្តែងនូវសេចក្តីសោមនស្សរីករាយដែលត្រូវបានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល អញ្ជើញឱ្យចូលរួមជាវាគ្មិនកិត្តិយសដើម្បីធ្វើបទបង្ហាញស្តីពីវឌ្ឍនភាពមូលដ្ឋាន ឃុំ សង្កាត់ និងទិសដៅការងារបន្តនាពេលនេះ ។

ក្នុងនាមរដ្ឋបាលខេត្តកំពង់ឆ្នាំង ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋទូទាំងខេត្តកំពង់ឆ្នាំង ខ្ញុំព្រះករុណា-ខ្ញុំបាទសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតគោរពជូនចំពោះការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**ដែលបានតស៊ូពុះពារគ្រប់ឧបសគ្គដើម្បីនាំយកសន្តិភាពជូនប្រទេស និងប្រជាពលរដ្ឋកម្ពុជាទាំងមូល “**សូមអរគុណសន្តិភាព**” ដែលបានធ្វើឱ្យប្រទេសកម្ពុជា មានស្ថេរភាពនយោបាយ មានសុខសុវត្ថិភាព និងការអភិវឌ្ឍលើគ្រប់វិស័យដូចសព្វថ្ងៃនេះ ។

ខ្ញុំព្រះករុណា-ខ្ញុំបាទ សូមគោរពរាយការណ៍ជូនសម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អំពីស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ សក្តានុពល សមិទ្ធផលនៃការអភិវឌ្ឍន៍ ស្ថានភាពសេដ្ឋកិច្ច ការគ្រប់គ្រងដឹកនាំ និងវឌ្ឍនភាពការងាររបស់ក្រុមប្រឹក្សាខេត្តកំពង់ឆ្នាំងសម្រេចបានក្នុងរយៈពេល ៣ឆ្នាំកន្លងមក ក្នុងអាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្ត ដូចតទៅ៖

## ១.អំពីភូមិសាស្ត្រខេត្តកំពង់ឆ្នាំង

ខេត្តកំពង់ឆ្នាំង ស្ថិតនៅចំកណ្តាល នៃប្រទេសកម្ពុជាក្នុងចំណោមរាជធានីខេត្តទាំង ២៥ មានចម្ងាយ ៩១ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានព្រំប្រទល់ខាងកើតទល់នឹង ខេត្តកំពង់ចាម-កំពង់ធំ ខាងលិចទល់នឹង ខេត្តពោធិ៍សាត់ ខាងត្បូងទល់នឹងខេត្តកំពង់ស្ពឺ-កណ្តាល ខាងជើងទល់នឹងខេត្តកំពង់ធំ-បឹងទន្លេសាប ។ រចនាសម្ព័ន្ធរដ្ឋបាលខេត្តចែកចេញជា ៧ស្រុក ១ក្រុង មាន ៧០ឃុំ-សង្កាត់ ចែកជា ៥៦៩ភូមិ មានប្រជាពលរដ្ឋរស់នៅចំនួន ១៣៦ ៩៥៨ គ្រួសារ ប្រជាពលរដ្ឋសរុប ៥៦៩ ៥៦៤ នាក់ ស្រី ២៩៤ ៤៦៣ នាក់ ដង់ស៊ីតេប្រជាជនក្នុងខេត្តមានចំនួន ១០៣ នាក់ ក្នុង ១គីឡូម៉ែត្រការ៉េ ។

ខេត្តកំពង់ឆ្នាំង មានប្រព័ន្ធផ្លូវគមនាគមន៍សំខាន់ៗ ៣ខ្សែ ឆ្លងកាត់គឺៈ កំណាត់ផ្លូវជាតិលេខ ៥ ប្រវែង ៩៤ គ.ម, ផ្លូវរថភ្លើង ប្រវែង ៧៣គ.ម និងផ្លូវទឹក( ទន្លេសាប ) ប្រវែង ១១០គ.ម ហូរឆ្លងកាត់ និងមាន ផ្ទៃដីសរុបទំហំ ៥៥២ ១០០ហិកតា ចែកជា ៣ផ្នែកគឺៈ-**តំបន់វាលទំនាប -តំបន់វាលរាប និងតំបន់ខ្ពង់រាប ។**

តាមលទ្ធផលនៃការគណនាផលិតផលក្នុងស្រុកសរុប ប៉ាន់ស្មានសេដ្ឋកិច្ចខេត្តឆ្នាំ២០២០ មានទំហំ ៨៥៩.៤ លានដុល្លារ ដែលចូលរួមពីវិស័យកសិកម្មមានសមាមាត្រចំនួន ៥៧,២%, ឧស្សាហកម្ម សិប្បកម្ម និងសំណង់មានសមាមាត្រចំនួន ២៥.៤% និងចំណូលពីវិស័យសេវាកម្ម ១៧,៤% ។ ផលិតផលក្នុងស្រុកសរុបផល(GDP)របស់ខេត្តនៅឆ្នាំ២០២០ សេដ្ឋកិច្ចខេត្តមានអត្រាកំណើន ០,៧% កំណើនសេដ្ឋកិច្ចខេត្តឆ្នាំ២០២០ មានអត្រាទាបជាងឆ្នាំកន្លងទៅដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ចំណូលប្រចាំឆ្នាំរបស់ប្រជាពលរដ្ឋម្នាក់ៗបានកើនឡើងចំនួន ១ ៤៩៨,១ដុល្លារ នៅឆ្នាំ២០២០ ធៀបនឹងឆ្នាំ២០១៩ មានចំនួន ១ ៤៨៧,៨ ដុល្លារ បើធៀបនឹងចំណូលមធ្យមសម្រាប់ម្នាក់ៗថ្នាក់ខេត្ត នៅទាបជាងថ្នាក់ជាតិនៅឡើយ ។ រីឯអត្រាភាពក្រីក្របានថយចុះពី ២០,៨២ % នៅឆ្នាំ ២០១៤ មកនៅត្រឹម ១៨,១៧% នៅឆ្នាំ២០២០ និងនៅឆ្នាំ ២០២១ មានចំនួន ១៨,៨៧% ដោយសារវិបត្តិ នៃជំងឺកូវីដ-១៩ ។ បើធៀបជាមួយថ្នាក់ជាតិ ការរីកចម្រើនសេដ្ឋកិច្ចរបស់ខេត្តនៅមានកម្រិតទាបជាងនៅឡើយ ។

## ២.វឌ្ឍនភាពការងាររបស់ក្រុមប្រឹក្សាខេត្តអាណត្តិទី៣

ក្រុមប្រឹក្សាខេត្តកំពង់ឆ្នាំង ដឹកនាំដោយឯកឧត្តម ឡុង ឈុនឡៃ ប្រធានក្រុមប្រឹក្សាខេត្ត និងមានសមាជិក សមាជិកាសរុប ២៣រូប ក្នុងនោះមានស្ត្រី ៤រូប ដែលភាគច្រើនជាអតីតថ្នាក់ដឹកនាំស្ថាប័នរដ្ឋ មានកម្រិតវប្បធម៌ចាប់ពីមធ្យមសិក្សាទុតិយភូមិរហូតដល់អនុបណ្ឌិត ។ ចំណែកគណៈអភិបាលខេត្ត មានចំនួន ៧រូប ដឹកនាំដោយ ឯកឧត្តម ស៊ុន សុវណ្ណារិទ្ធិ អភិបាល នៃគណៈអភិបាលខេត្ត មានអភិបាលរងខេត្តចំនួន ៦រូប អភិបាលរងជាស្ត្រី ១រូប ដែលសុទ្ធសឹងបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ បរិញ្ញាប័ត្រជាន់ខ្ពស់ និងបណ្ឌិតប្រកបដោយបទពិសោធន៍ និងទទួលបានការសិក្សាវគ្គខ្លី នៅក្រៅប្រទេសជាច្រើន។ ផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ថ្នាក់ដឹកនាំខេត្តកំពង់ឆ្នាំងមានចក្ខុវិស័យច្បាស់លាស់ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ដែលធ្វើឲ្យប្រជាពលរដ្ឋរស់នៅបានសុខសាន្តមានជីវភាពធូធារតាមរយៈកិច្ចការសំខាន់ៗដូចជា ការ អភិវឌ្ឍធនធានមនុស្ស ការពង្រឹងការដឹកនាំការអនុវត្តតួនាទី ភារកិច្ចស្របតាមជំនាញ និងបទពិសោធន៍ ការផ្លាស់ប្តូរទស្សនៈ ឥរិយាបថរបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៅក្រោមឱវាទ ដែលឈានទៅរកការផ្តល់សេវា ប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍន៍ប្រកបដោយសមធម៌ និងចីរភាព ។

**ក្រុមប្រឹក្សាខេត្តបានចូលរួមអនុវត្តនូវតួនាទី និងភារកិច្ចរបស់ខ្លួនដូចខាងក្រោមៈ**

-បានប្រជុំទៀងទាត់ស្របតាមប្រតិទិនស្តីពីកិច្ចប្រជុំសាមញ្ញ របស់ក្រុមប្រឹក្សា ការអនុវត្តតាមបទបញ្ជាផ្ទៃក្នុងដោយសង្កេតឃើញថាពីកិច្ចប្រជុំមួយទៅកិច្ចប្រជុំមួយមានការរីកចម្រើនលើការពិភាក្សាយ៉ាងផុលផុសលើវឌ្ឍនភាពការងាររបស់រដ្ឋបាលខេត្ត តាមរយៈការត្រួតពិនិត្យលើរបាយការណ៍ប្រចាំខែ

និងការឆ្លើយបំភ្លឺជូនអង្គប្រជុំពីបណ្តាមន្ទីរ អង្គភាពជំនាញ និងអ្នកពាក់ព័ន្ធប្រកបដោយការទទួលខុសត្រូវ

-មានបើកកិច្ចប្រជុំវិសាមញ្ញតាមការចាំបាច់របស់រដ្ឋបាលខេត្ត ផងដែរ

-មានការរៀបចំកិច្ចប្រជុំសម្ងាត់ដើម្បីវាយតម្លៃការតែងតាំង ផ្លាស់ប្តូរ មុខតំណែងមន្ត្រីស្របតាមលិខិតបទដ្ឋានគតិយុត្ត ប្រកបដោយតម្លាភាព និងយុត្តិធម៌

-បានរៀបចំបែងចែកការទទួលខុសត្រូវលើកិច្ចប្រតិបត្តិការ ដែលជួយសម្រួលដល់ការបំពេញតួនាទីភារកិច្ចរបស់ខ្លួនសម្រាប់ចុះមូលដ្ឋាន

-បានទទួលការបណ្តុះបណ្តាលជាបន្តបន្ទាប់ តាមរយៈវគ្គបណ្តុះបណ្តាលផ្សេងៗបានធ្វើឲ្យសមាជិកក្រុមប្រឹក្សាខេត្តមានការយល់ដឹងអំពីតួនាទីភារកិច្ចរបស់ខ្លួនបានល្អប្រសើរ

-ប្រធាន និងសមាជិកក្រុមប្រឹក្សា តែងតែចូលរួមរាល់សកម្មភាពនានាទាំងសកម្មភាពអភិវឌ្ឍន៍ សកម្មភាពសង្គម និងសកម្មភាពផ្នែកសាសនា ជាមួយថ្នាក់ដឹកនាំខេត្ត និងបានចែករំលែកព័ត៌មានដល់សមាជិកនានាក្នុងជួរក្រុមប្រឹក្សា

-បានរៀចំបង្កើតគណៈកម្មាធិការបោះឆ្នោតជ្រើស ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋ ថ្នាក់ខេត្ត ក្រុង ស្រុក ស្របតាមខ្លឹមសារអនុក្រឹត្យរបស់រាជរដ្ឋាភិបាល និងគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ

-កិច្ចការទំនាក់ទំនងរវាងគណៈអភិបាលខេត្ត និងក្រុមប្រឹក្សាខេត្តមានដំណើរការក្នុងស្មារតីសាមគ្គី និងឯកភាព មានភាពរលូនល្អ មិនតែប៉ុណ្ណោះទំនាក់ទំនងរវាងមន្ទីរអង្គភាពជំនាញជាមួយក្រុមប្រឹក្សាខេត្ត ក៏មានភាពល្អប្រសើរ ដោយក្រុមប្រឹក្សាបានអញ្ជើញតំណាងស្ថាប័នទាំងនេះ មកចូលរួមប្រជុំទៀងទាត់ដើម្បីរាយការណ៍

-ការគ្រោងថវិការប្រចាំឆ្នាំត្រូវបានពិភាក្សាដាក់ឆ្លងក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងមានការជជែកដេញដោល ដើម្បីសម្រេច ធានាបានការអនុវត្តការប្រើប្រាស់កញ្ចប់ថវិកាឱ្យបានចំគោលដៅ និងប្រកបដោយសមធម៌ និងប្រសិទ្ធភាព

-ក្រុមប្រឹក្សា ក្រុងស្រុកអាណត្តិទី៣ មានចំនួន ១៤០ នាក់

-ក្រុមប្រឹក្សា ឃុំ សង្កាត់អាណត្តិទី៤ មានចំនួន ៤២២ នាក់

-បានចូលរួមគាំទ្រសកម្មភាព ផអ៣ នៅថ្នាក់ខេត្ត និងនៅមូលដ្ឋាន(ក្រុងស្រុក និងឃុំ សង្កាត់)

-បានចូលរួមគាំទ្រដល់ការរៀបចំផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ(២០២០-២០២៤)ខេត្ត ក្រុង ស្រុក និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ និងបានចូលរួមគាំទ្រដល់ការរៀបចំបញ្ចប់ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឆ្នាំ២០២០-២០២៤ របស់ខ្លួន និងបានអនុម័តដោយក្រុមប្រឹក្សាខេត្ត

-ការគាំទ្រការរៀបចំ និងអនុវត្តគម្រោង ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ក្នុងឆ្នាំ២០២១៖

.គម្រោងរបស់រដ្ឋបាលខេត្ត មានចំនួន ៩គម្រោង

.គម្រោងរបស់ក្រុង ស្រុក ១៧គម្រោង

.គម្រោងឃុំសង្កាត់មាន ៥០ គម្រោង

-បានចូលរួមគាំទ្រមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សដោយផ្អែកតាមផែនការអន្តរាគមន៍អភិវឌ្ឍសមត្ថភាពស្ថាប័នខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ក្នុងរយៈពេល ២ឆ្នាំ(២០២០-២០២១) ចុងក្រោយក្រុមការងារ

បច្ចេកទេស បានបើកវគ្គបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធចំនួន ២៧វគ្គ ដែលមានអ្នកចូលរួមសរុប ៣ ៧៦៩នាក់ ក្នុងនោះជាស្ត្រីចំនួន ៩២០នាក់ ។

-ក្នុងអំឡុងពីខែមិថុនា ដល់ខែតុលា ឆ្នាំ២០២០ រដ្ឋបាលខេត្តបានចេញប្រតិបត្តិការបង្រ្កាប និងដកហូតដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ពីសំណាក់អ្នកទន្រ្ទានកាន់កាប់ដោយខុសច្បាប់យកមកគ្រប់គ្រងជាសម្បត្តិរដ្ឋវិញស្របតាមព្រះរាជក្រឹត្យចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការកំណត់ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ដែលកំពុងស្ថិតនៅជាធរមាននៅឡើយ ។

-បានចូលរួមក្នុងយុទ្ធនាការចុះពិនិត្យស្រាវជ្រាវ និងដកហូតដីដែលត្រូវបានជនខិលខូចកាប់ទន្រ្ទានកាន់កាប់យកធ្វើជាកម្មសិទ្ធិក្នុងតំបន់៣ នៃភូមិសាស្ត្រជុំវិញបឹងទន្លេសាបស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

## ៣.វេទិការពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាអាណត្តិទី៣ ឆ្នាំ២០២០ បានរៀបចំវេទិការផ្សព្វផ្សាយ និងពិគ្រោះយោបល់តាមបណ្តាក្រុង ស្រុក ទាំង៨ ដោយមានការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាក្រុមប្រឹក្សាខេត្ត , គណៈអភិបាលខេត្ត, នាយក នាយករងរដ្ឋបាលសាលាខេត្ត, នាយក នាយករងទីចាត់ការ និងអង្គភាពចំណុះសាលាខេត្ត, មន្ត្រី សាលាខេត្ត, មន្ទីរ អង្គភាពជុំវិញខេត្ត, សមាជិក សមាជិកាក្រុមប្រឹក្សាក្រុង ស្រុក, គណៈអភិបាលក្រុង ស្រុក, មន្ត្រី សាលាក្រុង ស្រុក, សមាជិក សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់, មេភូមិ គណៈកម្មាការ/សហគមន៍មូលដ្ឋាន, តំណាងអង្គការសង្គមស៊ីវិលក្នុងខេត្តសរុបចំនួន ១ ០៧១ នាក់ ស្រី ២៧២ នាក់។ ជាលទ្ធផលយើងទទួលបានសំណួរ-សំណូមពរសរុបចំនួន ៨៨ បកស្រាយបំភ្លឺ និងដោះស្រាយបានទាំង ៨៨ ដែលសំណួរ និងសំណូមពរ មានការពាក់ព័ន្ធ និងការសាងសង់ផ្លូវ ប្រព័ន្ធធារាសាស្រ្ត ទំនាស់ដីធ្លី ចរាចរណ៍ អនាម័យ បរិស្ថាន និងអគ្គីសនី ដែលស្ថិតក្នុងសមត្ថកិច្ច នៃរដ្ឋបាលខេត្តអាចសម្របសម្រួលបាន ។

ក្នុងឆ្នាំ២០២១កន្លងទៅក្រុមប្រឹក្សាខេត្តអាណត្តិទី៣ មិនអាចរៀបចំវេទិការផ្សព្វផ្សាយ និងពិគ្រោះយោបល់បាន ដោយសារការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍សហគម ២០កុម្ភៈ ។

## ៤.ការងារផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋតាមរយៈយន្តការអង្គភាព និងការិយាល័យច្រកចេញចូលតែមួយ

ក្នុងឆ្នាំ២០១៨កន្លងទៅ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវយន្តការដ៏មានប្រសិទ្ធភាពមួយដើម្បីផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ប្រកបដោយគុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ជាពិសេស គឺងាយស្រួលមិនសាំញ៉ាំ និងឆាប់រហ័ស ទប់ស្កាត់អំពើពុករលួយនោះគឺ យន្តការច្រកចេញចូល តែមួយ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ។អង្គភាព និងការិយាល័យច្រកចេញចូលតែមួយ មានតួនាទីភារកិច្ចជាអ្នកផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ដែលមានដាក់តារាងតម្លៃសេវា កំណត់ពេលវេលា ចំណែកការិយាល័យប្រជាពលរដ្ឋ ជាអ្នកទទួលពាក្យបណ្តឹងតាមដានការផ្តល់សេវា ហើយរាយការណ៍ជូនក្រុមប្រឹក្សាក្នុងករណីមានអំពើមិនត្រឹមត្រូវណាមួយកើតឡើង ដើម្បីក្រុមប្រឹក្សាណែនាំ និងប្រគល់ជូនគណៈអភិបាលខេត្ត ចាត់វិធានការណ៍ដោះស្រាយ ។

អង្គភាពច្រកចេញចេញចូលតែមួយបានខិតខំប្រឹងប្រែងផ្តល់សេវា ក្នុងនោះយើងទទួលបានសេវាចំនួន ២៤ ៧៨១ សេវា ដែលសរុបជាទឹកប្រាក់ចំនួនប្រមាណ ១ ៦៧៤ លានរៀល លើវិស័យជំនាញចំនួន

១៤ មាន៖ -សេវារដ្ឋបាល-នីត្យានុកូលកម្ម-វិស័យទេសចរណ៍-វិស័យវប្បធម៌ និងវិចិត្រសិល្បៈ-វិស័យបរិស្ថាន -វិស័យរ៉ែ និងថាមពល-វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់-វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-វិស័យកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ-វិស័យពាណិជ្ជកម្ម-វិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍-វិស័យព័ត៌មាន-វិស័យសាធារណការ និងដឹកជញ្ជូន-វិស័យសុខាភិបាល ។

**៥.ការងារប្រយុទ្ធប្រឆាំង នឹងការរីករាលដាល នៃជំងឺកូវីដ-១៩**

រដ្ឋបាលខេត្ត បានធ្វើសកម្មភាពអប់រំផ្សព្វផ្សាយពីវិធានការបង្ការជំងឺ កូវីដ-១៩ និងផ្សព្វផ្សាយពីការចាក់វ៉ាក់សាំងនៅគ្រប់ភូមិ ឃុំ ទូទាំងខេត្តតាមរយៈការចុះមូលដ្ឋាន និង ប្រើឧបករណ៍បំពងសំឡេង ដែលមានអាជ្ញាធរមូលដ្ឋានជួយសហការយ៉ាងសកម្ម ។ មានការរៀបចំជាប៉ុស្តិ៍ផ្តល់ថ្នាំបង្ការចំនួន ៥៣ក្រុម ចាក់ក្នុងនោះ ក្រុមគ្រូពេទ្យស្ម័គ្រចិត្តឯកឧត្តម **ហ៊ុន ម៉ានី** ចំនួន ១២ក្រុម កងទ័ពអាកាស ៣ក្រុម និងប្រតិបត្តិការសឹក រង ខេត្ត ២ក្រុម ។

បន្ទាប់ពីការប្រកាសបិទបញ្ចប់យុទ្ធនាការនៃការចាក់វ៉ាក់សាំងដល់ប្រជាជនអាយុ១៨ឆ្នាំឡើងរដ្ឋបាលខេត្ត បានបន្តរៀបចំក្រុមចាក់វ៉ាក់សាំងដែលមានទីតាំងនៅតាមមណ្ឌលសុខភាពទាំង ៤៩កន្លែង ដោយប្រើប្រាស់យន្តការ អនុគណកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងក្នុងក្របខ័ណ្ឌខេត្ត និងបានបង្កើតក្រុមការងារខេត្តចុះមូលដ្ឋានជួយជំរុញការចាក់វ៉ាក់សាំង នៅគ្រប់ ក្រុង ស្រុក ឃុំ សង្កាត់ និងជំរុញការចុះត្រួតពិនិត្យតាមខ្នងផ្ទះ បន្ថែមទៀត ។

-រដ្ឋបាលខេត្តបានរៀបចំមណ្ឌលចត្តាឡីស័កសម្រាប់ទទួលពលករ និងអ្នកចំណាកស្រុកដើម្បីធ្វើចត្តាឡីស័កមុនការចូលទៅរស់នៅក្នុងសហគមរបស់ពួកគាត់បានគ្រប់តាមតម្រូវការ និងទាន់ពេលវេលា ។

-ក្នុងបរិបទនៃការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ ព្រឹត្តិការណ៍ ២០កុម្ភៈ ទូទាំងខេត្តកំពង់ឆ្នាំងមានអ្នកវិជ្ជមានកូវីដ-១៩ សរុប ៤ ៧៨១ នាក់ ព្យាបាលឱ្យជាសះស្បើយសរុប ៤ ៦០៥ នាក់ មានអ្នកស្លាប់សរុប ១៧៥ នាក់ បច្ចុប្បន្ននៅសល់អ្នកដែលត្រូវបន្តសំរាកព្យាបាលចំនួន ១ នាក់ ។

-រដ្ឋបាលខេត្តបានអនុវត្តការងារចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនប្រជាពលរដ្ឋតាមប្រភេទអាយុជារួមអ្នកដែលត្រូវទទួលវ៉ាក់សាំងចាប់ពីអាយុ ៥ឆ្នាំ ឡើងយើងអនុវត្តបានរហូត ១០០,០១% លើសផែនការដែលបានគ្រោងទុក ក្នុងនោះ៖

១.អ្នកមានអាយុ ១៨ ឡើង ដែលត្រូវចាក់វ៉ាក់សាំងមាន ៣២៧ ២៣០ នាក់ បានចាក់ជូនប្រជាពលរដ្ឋបានចំនួន ៣៣២ ៨៥៥ នាក់ ស្មើ ១០១,៧២% លើសផែនការ

២.អ្នកមានអាយុពី១២ ដល់ក្រោម១៧ ឆ្នាំ ចំនួន ៦៥ ៤៣០នាក់ បានចាក់រួចចំនួន ៦៣ ៤២៤ នាក់ ស្មើ ៩៦,៩៣% ដែលនៅបន្តចាក់បន្ថែមទៀត ចំនួន ២ ០០៦ នាក់ ស្មើ ៣,០៧%

៣.អ្នកមានអាយុ ៦ ឆ្នាំដល់ ១២ ឆ្នាំ ដែលត្រូវទទួលវ៉ាក់សាំងចំនួន ៦៥ ៥៦៦ នាក់ បានចាក់រួចចំនួន ៦៨ ៩៤០ នាក់ ស្មើ ១០៥,១៥% លើសផែនការ

៤.អ្នកមានអាយុ ៥ ឆ្នាំ ដែលត្រូវទទួលវ៉ាក់សាំងចំនួន ចំនួន ១៥,៦៣១ នាក់ បានចាក់រួចចំនួន ៨ ៦៨២ នាក់ ស្មើ ៥៥,៥៤% ដែលនៅបន្តចាក់បន្ថែមទៀតចំនួន ៦ ៩៤៩ នាក់ ស្មើ ៤៤,៤៦%

**៦.យន្តការនៃការអនុវត្តការងាររបស់ក្រុមប្រឹក្សាខេត្ត ក្នុងការជំរុញ និងគាំទ្រដើម្បីប្រសិទ្ធភាពការងាររបស់មូលដ្ឋាន**

ដើម្បីឱ្យការអនុវត្តការងារឱ្យមានគុណភាព ប្រសិទ្ធភាព បរិយាប័ន្ន ក្នុងការគាំទ្រមូលដ្ឋាន ឃុំ សង្កាត់ រដ្ឋបាលខេត្តបានអនុវត្តតាមអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក។

**ការទំនាក់ទំនងការងារ របស់ក្រុមខេត្ត ជាមួយក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ មានដូចខាងក្រោម៖**

-ក្រុមប្រឹក្សាខេត្តបានសហការជាមួយក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុក ដើម្បីពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ទូទាំងខេត្ត ក្នុងគោលបំណងឆ្លើយតបតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ។

គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក មេឃុំ និងចៅសង្កាត់ មានភារកិច្ចអនុវត្តកិច្ចការប្រចាំថ្ងៃក្នុងការទំនាក់ទំនងទៅវិញទៅមករវាងខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់ក្នុងនាមក្រុមប្រឹក្សាខេត្ត ។

ក្នុងការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការខាងលើនេះ ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងខេត្តត្រូវទទួលខុសត្រូវ ៖ផ្តល់យោបល់ពិគ្រោះយោបល់ និងត្រួតពិនិត្យ ដើម្បីធានាថា ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុកនៅតែឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងខេត្តលើកសំណូមពរដល់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុកអំពីតម្រូវការនានារបស់ប្រជាពលរដ្ឋ ដែលក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់មិនអាចដោះស្រាយបានដោយសមត្ថភាព និងធនធានដែលខ្លួនមានធ្វើសហប្រតិបត្តិការឱ្យបានពេញលេញ ជាមួយក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុកក្នុងការលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍនៅមូលដ្ឋាន។

ក្រុមប្រឹក្សាខេត្តត្រូវបានទទួលការធ្វើប្រតិភូកម្មអំណាចក្នុងនាមរាជរដ្ឋាភិបាល ដើម្បីផ្តល់ការគាំទ្រនិងការត្រួតពិនិត្យនីត្យានុកូលភាពលើសេចក្តីសម្រេច និងសកម្មភាពរបស់រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ដើម្បីធានាថា រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ បំពេញមុខងារ និងភារកិច្ចដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្ម ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងស្របតាមគោលនយោបាយ របស់ជាតិ។ ការធ្វើប្រតិភូកម្មនេះ រួមមាន ៖

-ការវាយតម្លៃ និងការរៀបចំយុទ្ធសាស្ត្រសមស្របសម្រាប់ផ្តល់ការគាំទ្រខាងសមត្ថភាព ដល់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ព្រមទាំងមន្ត្រី បុគ្គលិករបស់ក្រុមប្រឹក្សាការណែនាំ និងសម្របសម្រួលគាំទ្រដល់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងការអនុវត្តមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ឱ្យ ស្របទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងគោលនយោបាយរបស់ជាតិ ។

-ត្រូវធានាថាក្រុង ស្រុកបានធ្វើការគាំទ្រយ៉ាងត្រឹមត្រូវដល់សង្កាត់ក្នុងក្រុង និងឃុំ សង្កាត់ក្នុងស្រុក ។ ក្រុមប្រឹក្សាខេត្ត ត្រូវបំពេញតួនាទីខាងលើនេះ លើមូលដ្ឋាននៃការធានាស្វ័យភាពរបស់ក្រុង ស្រុក ឃុំ និងសង្កាត់ ឱ្យស្របតាមគោលការណ៍នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ អនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្តនានា ។

-ក្រុមប្រឹក្សាខេត្តត្រូវធ្វើប្រតិភូកម្មអំពីការគាំទ្រ និងការត្រួតពិនិត្យនីត្យានុកូលភាពនេះដល់គណៈអភិបាលខេត្ត ដើម្បីអនុវត្តកិច្ចការ ប្រចាំថ្ងៃ។ គណៈអភិបាលខេត្តត្រូវស្នើសុំគោលការណ៍ណែនាំ និងធ្វើសេចក្តីរាយការណ៍អំពីការអនុវត្តតួនាទី និងភារកិច្ចខាងលើនេះ រៀងរាល់កិច្ចប្រជុំសាមញ្ញនៃក្រុមប្រឹក្សាខេត្ត ។ ក្នុងករណី

ចាំបាច់ ក្រុមប្រឹក្សាខេត្តអាចកោះប្រជុំវិសាមញ្ញ ដើម្បីពិនិត្យពិភាក្សា អំពីការគាំទ្រ និងការធ្វើប្រតិភូកម្មខាងលើនេះ។

អភិបាលខេត្តក្នុងនាមគណៈអភិបាលខេត្ត និងក្រុមប្រឹក្សាខេត្តជាអ្នកចុះហត្ថលេខាលើលិខិតបទដ្ឋានរដ្ឋបាលនានា ដើម្បីបម្រើឱ្យទំនាក់ទំនងខាងលើនេះ។

ក្រុមប្រឹក្សាខេត្តត្រូវបានទទួលប្រតិភូកម្មពីរាជរដ្ឋាភិបាល ដើម្បីផ្តល់ការគាំទ្រ ការសម្របសម្រួល និងការធ្វើសហប្រតិបត្តិការជាមួយរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ដើម្បីរួមគ្នាសម្រេចឱ្យបាននូវគោលនយោបាយរបស់ជាតិ ។

រដ្ឋបាលខេត្តបានបង្កើតក្រុមការងារទទួលសម្រួល និងដោះស្រាយរាល់បញ្ហាទំនាស់ សំណើ និងសំណូមពររបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានក្រុង ស្រុក ឃុំ សង្កាត់ ឃើញថាក្រុមការងារទទួលបានបណ្តឹង និងសំណូមពរសរុប ៧១៦ ក្រុមការងារបានដោះស្រាយរួចបានចំនួន ៥៨៩ កំពុងដោះស្រាយ ១១២ និងមិនទាន់ដោះស្រាយចំនួន ៩ និងបានបញ្ជូនសំណុំរឿងទៅស្ថាប័នតុលាការចំនួន ៦ ផងដែរ ។

## ៧.ការចាត់ឃុទ្ធនាការដកហូត និងគ្រប់គ្រងដីតំបន់៣ ជុំវិញបឹងទន្លេសាប

តាមរយៈអនុក្រឹត្យលេខ ១៩៧ អនក្រ.បក និងទិន្នន័យដែលទទួលបានពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ឆ្នាំង ព្រៃលិចទឹកតំបន់៣ ខេត្តកំពង់ឆ្នាំងមានផ្ទៃដីសរុបទំហំ ៧៥ ០២៨,១៣ ហិកតា គ្របដណ្តប់លើភូមិសាស្ត្រចំនួន ៣ ស្រុក រួមមានៈ

-ស្រុកកំពង់លែង មានផ្ទៃដីទំហំ ៦២ ០០៦, ៣៦ ហិកតា គ្របដណ្តប់លើ ៧ឃុំ មាន ២៧ភូមិ

-ស្រុកបរិបូណ៌ មានផ្ទៃដីទំហំ ៨ ៨៤៥,៧៧ ហិកតា គ្របដណ្តប់លើ ៧ឃុំ មាន ២០ភូមិ

-ស្រុកជលគីរី មានផ្ទៃដីទំហំ ៤ ១៧៦ ហិកតា គ្របដណ្តប់លើ ១ឃុំ មាន ២ភូមិ

ការងារចុះអនុវត្តយុទ្ធនាការដកហូតដីព្រៃលិចទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាបឃើញថា ប្រជាពលរដ្ឋស្ម័គ្រចិត្តធ្វើលិខិតប្រគល់ដីជូនរដ្ឋសរុបចំនួន ៧ ៥៣១គ្រួសារ លើផ្ទៃដីប្រកាសក្នុងលិខិតស្ម័គ្រចិត្តសរុបទំហំ ៣០ ៥៨៩ហិកតា ក្នុងនោះស្រុកកំពង់លែងចំនួន ៥ ០៨៥គ្រួសារ ផ្ទៃដីប្រកាសសរុបទំហំ ២៤ ០៩៥,៣២ ហិកតា ស្រុកបរិបូណ៌ ចំនួន ២ ០៥៣គ្រួសារ ផ្ទៃដីប្រកាសសរុបទំហំ ៤ ៩៩៩,៩៤ហិកតា និងស្រុកជលគិរី ចំនួន ៣៩៧គ្រួសារ ផ្ទៃដីសរុប ១ ៤៩៣,៧៤ហិកតា ។

ក្រុមការងារបានចុះវាស់វែងក្បាលដីតាមការចង្អុលបង្ហាញ របស់ប្រជាពលរដ្ឋដែលបានស្ម័គ្រចិត្តប្រគល់ដីជូនរដ្ឋរួចចំនួន ៣ ៧៨៨ គ្រួសារ ស្មើនឹង ៤ ២៩០ក្បាលដី លើផ្ទៃដីសរុបទំហំ ១១ ៥៧៦,៣៨ ហិកតា ក្នុងនោះ ស្រុកកំពង់លែងចំនួន ១ ៦៧០គ្រសារ ស្មើនឹង ១ ៨០៨ក្បាលដី សរុបទំហំ ៦៧២៥, ៦៣ ហិកតា ស្រុកបរិបូណ៌ចំនួន ១ ៨១៣ គ្រួសារ ស្មើនឹង ២ ១៤៩ ក្បាលដី សរុបទំហំ ៣ ៧៦៦,១៧ហិកតា និងស្រុកជលគិរីចំនួន ៣០៥ គ្រួសារ ស្មើនឹង ៣៣៣ ក្បាលដី សរុបទំហំ ១ ០៨៤,៥៨ហិកតា ។

ក្នុងយុទ្ធនាការនេះផងដែរក្រុមការងារបានចាត់វិធានការដោយបានរុះរើរោងចំនួន ៥៥រោង និងបានដកបង្គោលកំណត់ព្រំដី ២២៣បង្គោល បញ្ចប់តាមផែនការ ១០០% ស្ថិតក្នុងឃុំប្រណុក ស្រុកកំពង់លែង ។

ក្រុមការងារក៏បានដាក់ប៉ាណូកំណត់ព្រំប្រទល់តំបន់ ៣ បានចំនួន ០៤ ទីតាំង

ទី១-តាមបណ្តោយផ្លូវលេខ ៥OC (ផ្លូវកំពង់ឆ្នាំង-កំពង់ធំ) ក្នុងភូមិកង្កែប ឃុំប្រណុក

ទី២-នៅតាមបណ្តោយផ្លូវចូលទៅឃុំផ្លូវទូក

ទី៣-នៅតាមបណ្តោយផ្លូវចូលទៅភូមិសេះស្លាប់

ទី៤-នៅតាមបណ្តោយផ្លូវចូលទៅឃុំផ្លុកទ្រូ ។

បានដាំកូនឈើក្នុងតំបន់ព្រៃលិចទឹកឡើងវិញចំនួន ២៣ ២៤៤ ដើម និងកប់គ្រាប់ត្នោតនៅតាមព្រំប្រទល់ព្រៃលិចទឹកតំបន់៣បាន ១១ ៣៣៤ គ្រាប់ នៅក្នុងភូមិសាស្ត្រស្រុកបរិបូណ៌ និងស្រុកកំពង់លែង ។

**៨.ទិសដៅការងាររបស់ក្រុមប្រឹក្សាខេត្ត**

-ត្រៀមរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត និងរៀបចំផែនការចុះគាំទ្រនៅមូលដ្ឋានដើម្បីប្រមូលតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ក្នុងការអនុវត្តនូវមុខងារជាជម្រើសរបស់ក្រុមប្រឹក្សា ។

-បន្តការគាំទ្រក្នុងការអនុវត្តមុខងារ ដែលបានប្រគល់ដោយក្រសួងស្ថាប័ន ថ្នាក់ជាតិ ។

-ជំរុញ និងគាំទ្រការអនុវត្តក្របខណ្ឌការងារគណនេយ្យភាពសង្គម និងយន្តការច្រកចេញចូលតែមួយដើម្បីបង្ខិតសេវាសាធារណៈឱ្យកៀក នឹងប្រជាពលរដ្ឋនៅមូលដ្ឋានប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ។

-បន្តពង្រឹងគោលនយោបាយរៀបចំផែនការអភិវឌ្ឍន៍ និងការកសាងកម្មវិធីវិនិយោគខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ឱ្យមានសង្គតិភាព និងការរៀបចំយុទ្ធសាស្ត្រថវិកា ឱ្យសមស្របទៅតម្រូវការក្នុងការអភិវឌ្ឍន៍។

-បន្តការរៀបចំ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល ឱ្យទាន់ពេលវេលា និងការរៀបចំផែនការថវិកាប្រចាំឆ្នាំ។

-ពង្រឹងការអនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឱ្យស្របតាមលិខិតបទដ្ឋានគតិយុតនានា និងបែងចែកភារកិច្ចចូលរួមគាំទ្រការងាររាល់ការចេញសេចក្តីសម្រេច របស់អង្គប្រជុំក្រុមប្រឹក្សា។

-បន្តការគាំទ្រយន្តការសម្រុះសម្រួល និងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងតាមរយៈការិយាល័យប្រជាពលរដ្ឋ

-ពង្រឹងទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាល និងគាំទ្រក្នុងការកៀគរ ធនធានដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក្នុងមូលដ្ឋាន ។

-រៀបចំតាមដានត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំ ក្នុងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឱ្យបានទៀងទាត់។

-ជំរុញការអនុវត្តនូវគោលការណ៍រដ្ឋបាលឯកភាព និងគោលនយោបាយភូមិឃុំ មានសុវត្ថិភាព។

-បន្តការគាំទ្រយន្តការមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីពង្រឹងសមត្ថភាពដល់រដ្ឋបាលខេត្ត ក្រុង ស្រុក និង ឃុំ សង្កាត់។

ដើម្បីអនុវត្តនូវយន្តការ នៃការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិរបស់ខ្លួន ក្រុមប្រឹក្សាខេត្តពកំពង់ឆ្នាំងមាន គណៈកម្មាធិការនានា ចំនួន ៣ ដើម្បីអនុវត្តនូវតួនាទីភារកិច្ចការងារជាប់ជាប្រចាំមាន៖

-គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

-គណៈកម្មាធិការលទ្ធកម្ម

-គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

ក្នុងនោះរដ្ឋបាលខេត្តមានការិយាល័យប្រជាពលរដ្ឋខេត្ត និងទីចាត់ការ និងអង្គភាពចំណុះសាលាខេត្ត ចំនួន៧ គឺ៖

-ទីចាត់ការរដ្ឋបាល

-ទីចាត់ការផែនការ និងវិនិយោគ

-ទីចាត់ការគ្រប់គ្រងធនធានមនុស្ស

-ទីចាត់ការហិរញ្ញវត្ថុ
-ទីចាត់ការអន្តរវិស័យ
-អង្គភាពលទ្ធកម្ម និង
-អង្គភាពច្រកចេញចូលតែមួយខេត្ត

រដ្ឋបាលខេត្តកំពង់ឆ្នាំង មានក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ដែលគាំទ្រដោយក្រុមការងារគណបក្សប្រជាជនកម្ពុជាដឹកនាំដោយ**សម្តេចចៅហ្វាវាំង គង់ សំអុល ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង** និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តដឹកនាំដោយ**ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ** បានធ្វើឲ្យខេត្តកំពង់ឆ្នាំងមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ធានាបាននូវសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងមានកិច្ចសហប្រតិបត្តិការល្អ រួមនិងការអភិវឌ្ឍសមត្ថភាពផ្នែកសេដ្ឋកិច្ច សង្គម វិស័យឯកជន វិស័យការងារ និងការគ្រប់គ្រងដីធ្លីធនធានធម្មជាតិ បរិស្ថាន និងការដោះស្រាយទំនាស់ដីធ្លី ទទួលបានលទ្ធផលល្អជាបន្តបន្ទាប់ ។ ជាមួយនេះបានជំរុញការអភិវឌ្ឍមូលដ្ឋាន និងការលើកកម្ពស់ស្ថានភាព ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានភាពប្រសើរជាបន្តបន្ទាប់ ពីមួយឆ្នាំទៅមួយឆ្នាំ ។

ក្នុងនាមរដ្ឋបាលខេត្ត ខ្ញុំព្រះករុណា ខ្ញុំបាទសូមប្តេជ្ញាថា នឹងខិតខំបន្តចូលរួមអនុវត្តតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីធានាបាននូវការរក្សានូវសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម បង្កើនបាននូវគុណភាព នៃការផ្តល់សេវាប្រកបដោយគណនេយ្យភាព តម្លាភាព សុចរិតភាព មានការអភិវឌ្ឍប្រកបដោយចីរភាព ជូនដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ។

ជាសំណូមពរក្នុងឱកាសនេះ សូមឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី មេត្តាអញ្ជើញចូលរួមពិនិត្យ សិក្សាស្វែងយល់ដើម្បីចូលរួមអភិវឌ្ឍខេត្តកំពង់ឆ្នាំងឱ្យកាន់តែមានការរីកចម្រើនលើគ្រប់វិស័យបន្ថែមទៀត ។

ជាទីបញ្ចប់ ខ្ញុំសូមបួងសួងប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការ និង សូមគោរពជូនពរ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងអង្គសន្និសីទទាំងមូល ព្រមទាំងទូរទស្សនិកជនកំពុងតាមដានទស្សនាការផ្សាយផ្ទាល់ទាំងអស់ សូមសមប្រកបនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមជៀសឆ្ងាយពីជំងឺកូវីដ-១៩ ទាំងអស់គ្នា ។

*សូមអរគុណ!*